ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ 0053 អ.ប.ស ឱអបស រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ០២ ឆ្នាំ ២០០៩

# ប្រកាស

## ស្តីពី

## ការកែសម្រួលប្រកាសលេខ ៨៣ អបស/ឱអបស ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសុខាភិបាល ស្តីពី លក្ខខណ្ឌក្នុងការផ្សព្វផ្សាយឱសថ និងផលិតផល ដែលមានគុណភាពក្នុងការបង្ការឬព្យាបាលជំងឺ

រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម នស /រកម /០១៩៦ /០២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញ ព្រះរាជក្រម ជស /រកម /០៦៩៦ /០២ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រម រស/រកម /១២០៧ /០៣៧ ចុះថ្ងៃទី ២៨ ធ្នូ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ តុលា ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃក្រសួងសុខាភិបាល
- បានឃើញ ប្រកាសរបស់ក្រសួងសុខាភិបាល លេខ ៨៣ អបស/ ឱអបស ចុះថ្ងៃទី ៣១ មីនា ១៩៩៩ ស្តីពីល័ក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយឱសថ និងផលិតផលដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជម្ងឺ
- និងយោងតាមការរៀបចំរបស់ក្រសួងសុខាភិបាល ។

<u>សម្រេច</u>

ប្រការ១: ខ្លឹមសារប្រកាសលេខ ៨៣ អបស/ ឱអបស ចុះថ្ងៃទី ៣១ មីនា ១៩៩៩ របស់ក្រសួងសុខាភិបាល ត្រូវបានកែសម្រួលដូចខាងក្រោម ។

ប្រការ២: ការផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ ឱសថបូរាណ ផលិតផលបំប៉នសុខភាព ស្រាថ្នាំបូរាណគ្រប់ប្រភេទ សម្ភារៈ បរិក្ខាពេទ្យ-ទន្តពេទ្យ សម្ភារៈប្រតិករសម្រាប់មន្ទីរពិសោធន៍វេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ គ្រឿងសម្អាង និងផលិតផលដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជម្ងឺ តាមរយៈទូរទស្សន៍ វិទ្យុ សារព័ត៌មាន ទស្សនាវដ្ដី ព្រឹត្តប័ត្រវេជ្ជសាស្ត្រ-ឱសថាសាស្ត្រ-ទន្តសាស្ត្រ ប័ណ្ណប្រកាសរូបភាព សិក្ខាសាលា ទិវាវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ឬតាមរូបភាពផ្សេងៗទៀតអាចប្រព្រឹត្តទៅបានលុះត្រាតែមានការ អនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ៣: ឱសថ ផលិតផលបំប៉នសុខភាព បរិក្ខាពេទ្យ គ្រឿងសម្អាង និងផលិតផលដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជម្ងឺអាចសុំធ្វើការផ្សព្វផ្សាយបាន លុះត្រាតែមានវិញ្ញាប័ណ្ណប័ត្រទិដ្ឋាការ ឬបញ្ជិកា ឬប្រវេទន៍ចេញដោយក្រសួងសុខាភិបាល ។

ប្រការ៤: ចំពោះឱសថសម័យ ឱសថបូរាណ លក់ដោយមិនចាំបាច់មានវេជ្ជបញ្ជា (OTC) ស្រាថ្នាំបូរាណគ្រប់ប្រភេទ ផលិតផលបំប៉នសុខភាព សម្ភារៈបរិក្ខាពេទ្យ គ្រឿងសម្អាង និងផលិតផលអនាម័យ សាម៉ីជនអាចសុំធ្វើការផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុសារព័ត៌មាន ទស្សនាវដ្ដី ឬប័ណ្ណប្រកាសរូបភាព ដែលមានទំហំត្រឹមក្រដាស A4 សម្រាប់ចែកដល់អ្នកបច្ចេកទេសសុខាភិបាល និងដាក់តាមគ្លីនិគ ឱសថស្ថាន ឱសថស្ថានរង សម្រាប់អតិថិជនបានយល់ដឹង ប្រតិទិន សម្ភារៈប្រើប្រាស់ផ្សេងៗមានជាអាវ៍ កែវទឹក នាឡិកា ។ល។ និងសម្ភារៈការិយាល័យគ្រប់ប្រភេទ ។

ប្រការ៥: ចំពោះផលិតផលបំប៉នសុខភាព សម្ភារៈបរិក្ខាពេទ្យ-ទន្តពេទ្យ សម្ភារៈប្រតិករសម្រាប់មន្ទីរពិសោធន៍ វេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ គ្រឿងសម្អាង និងផលិតផលអនាម័យ ដែលពុំមានគុណវិបត្តិធ្ងន់ធ្ងរដល់ អ្នកប្រើប្រាស់ សាម៉ីជនអាចសុំធ្វើការផ្សាព្វផ្សាយតាមផ្ទាំងរូបភាពធំៗ (Panneau) ទំហំ ៤ម៉ែត្រ គុណ ៨ម៉ែត្រ ។

ប្រការ៦: ចំពោះឱសថដែលផ្សំឡើងដោយមានសារធាតុគ្រោះថ្នាក់ (លក់ត្រូវមានវេជ្ជបញ្ជា) ឱសថញៀន ឱសថប្រព័ន្ធសរសៃប្រសាទ ឱសថពន្លូតកូន (Abotifs) ឱសថព្យាបាលជម្ងឺកាមរោគ អេដស៍ មហារីក ឱសថប្រើសម្រាប់តែទារក ឱសថបង្កើនតណ្ហា (aphrodisiaque) សាម៉ីជនមិនអាចសុំធ្វើការផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ សារព័ត៌មាន ទស្សនាវដ្ដី ឬប្រតិទិនបានទេ ។ ការផ្សព្វផ្សាយផលិតផលខាងលើ ដល់អ្នកបច្ចេកទេសសុខាភិបាលអាច ធ្វើបានតាមរយៈ សិក្ខាសាលា ទិវាវេជ្ជសាស្ត្រ-ឱសថាសាស្ត្រ-ទន្តសាស្ត្រ ឬព្រឹតិប័ត្រវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ឬប័ណ្ណប្រកាសរូបភាព (Brochure) ដែលមានទំហំត្រឹមក្រដាស A4 សម្ភារៈ ប្រើប្រាស់ផ្សេងៗ និង សម្ភារៈការិយាល័យ គ្រប់ប្រភេទ ដោយគ្រាន់តែដាក់ឈ្មោះឱសថ សំរាប់ចែកដល់អ្នកបច្ចេកទេសសុខាភិបាល ។

ប្រការ៧: អត្ថបទ និងរូបភាពដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ ឱសថបូរាណ ផលិតផលបំប៉នសុខភាព ស្រាថ្នាំបូរាណគ្រប់ប្រភេទ សម្ភារៈបរិក្ខាពេទ្យ-ទន្តពេទ្យ សម្ភារៈប្រតិករសម្រាប់មន្ទីរពិសោធន៍វេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ គ្រឿងសម្អាង និងផលិតផលដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជម្ងឺ តាមរយៈទូរទស្សន៍ វិទ្យុ សារព័ត៌មាន ទស្សនាវដ្ដី ព្រឹត្តិប័ត្រវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ ប័ណ្ណប្រកាសរូបភាព សិក្ខាសាលា ទិវាវេជ្ជសាស្ត្រ-សថសាស្ត្រ-ទន្តសាស្ត្រ ឬតាមរូបភាពផ្សេងៗទៀត ត្រូវ

ឆ្លងការត្រួតពិនិត្យ និងមានការឯកភាពពីក្រសួងសុខាភិបាល ។ ខ្លឹមសារផ្សព្វផ្សាយត្រូវមានលក្ខណៈត្រឹមត្រូវតាមឯកសារវេជ្ជសាស្ត្រ-ឱសថសាស្ត្រ-ទន្តសាស្ត្រ និងជៀសវាងការឃោសនាបំផ្លើស ប្រាសចាកពីខ្លឹមសារ ដែលមានការយល់ព្រមពីក្រសួងសុខាភិបាល ។

ប្រការ៨: ការសុំផ្សព្វផ្សាយពាណិជ្ជកម្មឱសថ ផលិតផលបំប៉នសុខភាព គ្រឿងសម្អាង បរិក្ខាពេទ្យ ត្រូវបំពេញសុំណុំលិខិតដូចខាងក្រោម:

ក-ករណីផ្សព្វផ្សាយតាមទូរទស្សន៍ ឬវិទ្យុ

- ពាកសុំផ្សព្វផ្សាយនិង កិច្ចសន្យា — ១ច្បាប់ (មានគំរូ)
- វិញ្ញាបនប័ត្រ ទិដ្ឋាកា ឬប្រវេទន៍ (ថតចម្លង) — ១ច្បាប់
- សេចក្តីព្រាងអត្ថបទផ្សព្វផ្សាយ — ១ច្បាប់
- កាសែតវីដេអូ DVD ឬ VCD ឬ CD ជា SPOT គំរូ — ១ច្បាប់
- ឱសថគំរូព្រមទាំងបរិយាយប័ណ្ណឱសថជាភាសាខ្មែរ — ១ឯកតា

ខ-ករណីផ្សព្វផ្សាយតាមសារព័ត៌មាន ឬទស្សនាវដ្តី ឬប្រតិទិន ឬសៀវភៅផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬ ប័ណ្ណប្រកាសរូបភាព

- ពាក្យសុំផ្សព្វផ្សាយ និងកិច្ចសន្យា — ១ច្បាប់ (មានគំរូ)
- វិញ្ញាបនប័ត្រ ទិដ្ឋាកា ឬប្រវេទន៍ (ថតចម្លង) — ១ច្បាប់
- សេចក្តីព្រាងអត្ថបទ និងរូបភាពផ្សព្វផ្សាយ — ១ច្បាប់
- ឱសថគំរូព្រមទាំងបរិយាយប័ណ្ណឱសថជាភាសាខ្មែរ — ១ឯកតា

គ-ករណីធ្វើសោភ្ជាសាលា ឬប្រជុំគុម្ពល

- ពាក្យសុំផ្សព្វផ្សាយ — ១ច្បាប់ (មានគំរូ)
- វិញ្ញាបនប័ត្រ ទិដ្ឋាកា ឬប្រវេទន៍ (ថតចម្លង) — ១ច្បាប់
- កម្មវិធី — ១ច្បាប់

ប្រការ៩: លិខិតអនុញ្ញាតផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី មានសុពលភាពរយៈពេល ៦ខែ លើកលែងតែប្រតិទិនដែលមានសុពលភាព ១ឆ្នាំ ។ សម៉ីជនអាចសុំបន្តការផ្សព្វផ្សាយសារឡើងវិញ ១ខែ មុនពេលអស់សុពលភាព ។

ប្រការ១០: ការផ្សព្វផ្សាយដែលត្រូវហាមឃាត់:

- ប្រើឧគ្ហោសនស័ព្ទតាមទីសាធារណៈ រោងល្ខោន រោងកុន ផ្សារណាត់
- បិទតាមទូរទស្សន៍សាធារណៈ មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ
- បោះពុម្ពលើអាវយឺត អាវភ្លៀង ឆ័ត្រ មួក
- ធ្វើជាបដាចងកាត់ទទឹងថ្នល់ តាមបង្គោលភ្លើង ឬទីសាធារណៈ ឬតាមអគារផ្សេងៗ
- បិទលើឆលកពេលប្រគុំតន្ត្រី ពេលធ្វើសម្ភាសន៍ ឬក្នុងកម្មវិធីផ្សេងៗ តាមប៉ុស្តិ៍ទូរទស្សន៍នានា

- បិទក្បែរស្លាកសញ្ញាឱសថស្ថាន-រង ឬធ្វើជាស្លាកសញ្ញាឱសថស្ថាន-រង
- បិទតាមទូថ្នាំជារនាំងបាំងថ្ងៃ ជាប្រអប់ភ្លើង ជាផ្ទាំងរូបភាពបិទ ឬបញ្ចរមុខឱសថស្ថាននិង គ្រឹះស្ថានផ្សេងៗទៀត
- ការសម្ភាសន៍របស់ពិធីករ ពិធីការិនី តាមវិទ្យុ ទូរទស្សន៍ និងតាមគ្រប់រូបភាពដែលមានបំណងផ្សព្វផ្សាយពាណិជ្ជកម្ម
- ការធ្វើអត្ថធិបាយបន្ថែម របស់សិល្បៈករ សិល្បៈការិនី ពិធីករ ពិធីការិនី
- ឬតាមរូបភាពផ្សេងៗទៀត ដែលគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

ប្រការ១១: ក្រសួងសុខាភិបាលមានសិទ្ធដកហូតវិញនូវលិខិតអនុញ្ញាតផ្សព្វផ្សាយ ក្នុងករណីពិនិត្យឃើញថា
- ខ្លឹមសារនិង រូបភាពផ្សព្វផ្សាយមានលក្ខណៈខុសពីការយល់ព្រមរបស់ក្រសួងសុខាភិបាល
- ឬផលិតផលនោះអាចបង្ករគ្រោះថ្នាក់ដល់សុខភាពតាមការផ្តល់ព័ត៌មានពីក្រសួងមានសមត្ថកិច្ច

ប្រការ១២: ការប្រព្រឹត្តល្មើសនិងប្រការនេះត្រូវផ្តន្ទាទោសតាមបញ្ញាត្តិដែលមានចែងក្នុងច្បាប់ ស្តីពីការគ្រប់គ្រងឱសថ ។

ប្រការ១៣: អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋាន នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យ និង គ្រឿងសំអាងមានភារៈកិច្ចត្រួតពិនិត្យតាមដានការអនុវត្តន៍ ប្រកាសនេះអោយមានប្រសិទ្ធភាពតាមភារៈកិច្ច រៀងៗខ្លួន ។

ប្រការ១៤: បទបញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីប្រការនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៥: ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងជូនៈ**

- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណរដ្ឋមន្ត្រី
- ក្រសួងព័ត៌មាន
- សាលាក្រុងភ្នំពេញ
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- អគ្គនាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ
- អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
- នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខាពេទ្យ និងគ្រឿងសំអាង
- មន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងខេត្ត-ក្រុង
- ឯកសារ
- កាលប្បវត្ត

**ម៉ម ប៊ុនហេង**